ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ: ០១១/១៥ អ.ព.ប.ហ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥

ថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៥ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។**

**២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ។**

**៣- បញ្ហាផ្សេងៗ**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័តៈ

**១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។**

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងទទួលផលពីសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ។

ឆ្នាំ២០១៦ គឺជាបង្គោលចរដ៏មានអត្ថន័យបំផុត ដែលនឹងកត់ត្រាទុកនូវការឈានឡើងរបស់កម្ពុជានៅក្នុងសតវត្សទី២១នេះ ពោលគឺ កម្ពុជានឹងចាកចេញផុតពីចំណាត់ថ្នាក់ជាប្រទេសដែលមានប្រាក់ចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប ហើយក៏ជាឆ្នាំនៃការចាប់ផ្តើមនៃដំណើរផ្លាស់ប្តូររបស់កម្ពុជា នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ ក្នុងដំណើរឆ្ពោះទៅសម្រេចឲ្យបាននូវចក្ខុវិស័យអភិវឌ្ឍន៍របស់ខ្លួន ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីធានាបាននូវដំណើរផ្លាស់ប្តូរមួយ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ បានកំណត់ថវិកាសរុប ១៧៦១២ ៤៧៧ លានរៀល។ នៅក្នុងក្របខណ្ឌនេះ កម្ពុជាត្រូវធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧%ក្នុងមួយឆ្នាំ ដែលធ្វើឲ្យ កំណើនសេដ្ឋកិច្ចសរុប ក្នុងស្រុក (ផ.ស.ស) តាមថ្លៃបច្ចុប្បន្នមានចំនួន ៨១៩៣៤៣៣៣ លានរៀល ប្រមាណជា២០២៣១ លានដុល្លារអាមេរិក។ ប្រការនេះធ្វើឲ្យផ.ស.ស សម្រាប់មនុស្សម្នាក់ នឹងកើនដល់ ១៣២៥ដុល្លារអាមេរិក។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ជាមូលដ្ឋានមិនអាចខ្វះបានសម្រាប់ការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យ ព្រមទាំងការបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទូទៅឲ្យកាន់តែប្រសើរឡើង។ សេចក្តីព្រាងច្បាប់នេះបានសម្រេច លុបចោលរបបពន្ធមៅការ លុបចោល និងកែសម្រួលនូវប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនមួយចំនួន តម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ ក៏ដូចជាដាក់ចេញនូវវិធានការពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ប្រយុទ្ធប្រឆាំង និងអំពើពុករលួយ ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ៤យ៉ាងគឺ «ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល» ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃសេវាសាធារណៈ ព្រមទាំងការធ្វើឲ្យកាន់តែប្រសើរឡើងនូវបរិស្ថានវិនិយោគ និងធុរកិច្ច។ ដោយសារឆ្នាំ២០១៦ ក៏ជាឆ្នាំទី១ នៃការចាប់ផ្តើមរបស់សហគមន៍សេដ្ឋកិច្ចអាស៊ានកម្ពុជាក៏មានភាពចាំបាច់ត្រូវរៀបចំខ្លួនឲ្យបានល្អ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង ពិសេសការបន្តនូវការកែទម្រង់សំខាន់ៗស្របតាមតម្រូវការ ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីសហគមន៍សេដ្ឋកិច្ចនេះ និងត្រូវបន្តធ្វើការកែទម្រង់លើគ្រប់វិស័យឲ្យបានខ្លាំងក្លា និងស៊ីជម្រៅបន្ថែមទៀត ដើម្បីភាពប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគ និងបង្កើនតម្លៃបន្ថែមឲ្យបានខ្ពស់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ឲ្យមានចីរភាព។ ដើម្បីគោលដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ ហើយឆ្នាំ២០១៦ ក៏ជាឆ្នាំនៃការចាប់ផ្តើមជំរុញយ៉ាងសកម្មនូវការអនុវត្តគោលនយោបាយដ៏មានសារៈសំខាន់នេះផងដែរ។ ក្នុងន័យនេះ ឆ្នាំ២០១៦ ត្រូវតែជាឆ្នាំនៃការប្រមូលពួតផ្តុំនូវកម្លាំង និងធនធាន ក្នុងការសម្រេចឲ្យបាននូវសមិទ្ធផលសំខាន់ៗបន្ថែមទៀត។

## ២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផល នៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានរួមចំណែកយ៉ាងសំខាន់គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តនូវកម្មវិធីនយោបាយរបស់ខ្លួនប្រកបដោយជោគជ័យ ដែលឆ្លុះបញ្ចាំងតាមរយៈការសម្រេចបាននូវគោលដៅធំៗ ក្នុងការបន្តពង្រឹងសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងអភិបាលកិច្ច និងការកែទម្រង់ស្ថាប័នជាតិសំខាន់ៗ។

ចំណូលថវិកាថ្នាក់ជាតិឆ្នាំ ២០១៤ អនុវត្តបានចំនួន ១៥២៧០៩៤០,៨លាន ស្មើនឹង២២,៥៤% នៃផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ១១,៥% ហើយបានកើនឡើង២៤,៤ ធៀបនឹងការអនុវត្តឆ្នាំ ២០១៣។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៤ បានបង្ហាញឲ្យឃើញថា ដោយសារធាតុចូលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ប្រកបដោយប្រសិទ្ធភាព

ភាព រាជរដ្ឋាភិបាលកម្ពុជា អាចសម្រេចបាននូវសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ដូចជា៖ (១)-កំណើនសេដ្ឋកិច្ចសម្រេចបាន ៧,១% នៃផ.ស.ស. ធៀបនឹងការគ្រោងទុកប្រមាណ ៧% នៃ ផ.ស.ស.(២)-ផ.ស.ស. សម្រាប់មនុស្សម្នាក់ៗ សម្រេចបាន១១៣៨ ដុល្លារអាមេរិក (៣)-អតិផរណារក្សាបាន ៣,៩% ធៀបនឹងការគ្រោងទុក គឺក្នុងរង្វង់ ៣,៥% (៤)-អត្រាប្តូរប្រាក់ សម្រេចបានជាមធ្យម ៤០៣៩រៀល ក្នុងមួយដុល្លារអាមេរិក ធៀបនឹងការគ្រោងទុក ៤០៥០រៀល ក្នុងមួយដុល្លារអាមេរិក (៥)-កំណើនចំណូលសរុបសម្រេចបាន ១,៨៩ពិន្ទុភាគរយនៃ ផ.ស.ស. ធៀបនឹងការគ្រោងទុក ០,៥ ពិន្ទុភាគរយនៃ ផ.ស.ស. ដែលធ្វើឲ្យមានការសន្សំអតិរេកថវិកា បានចំនួន ១ ២០៣ ០០៨,៨ លានរៀល។ ការអនុវត្តគោលនយោបាយចំណាយថវិកាឆ្នាំ ២០១៤ទទួលបានលទ្ធផលល្អ ដោយបានបំពេញតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ចំពោះមុខដែលបានកើតឡើងជាពិសេស៖

-រាជរដ្ឋាភិបាលបានដំឡើងប្រាក់បៀវត្សមូលដ្ឋានប្រចាំខែជូនមន្ត្រីរាជការស៊ីវិល ដំឡើងប្រាក់ឧបត្ថម្ភគ្រូចូលនិវត្តបម្រើការងារជាគ្រូជាប់កិច្ចសន្យា និងប្រាក់ហូបប្រចាំថ្ងៃរបស់កងកម្លាំងប្រដាប់អាវុធ។ លើសពីនេះ ការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែ ជូនមន្ត្រីរាជការក្នុងឆ្នាំ ២០១៤ នេះ អនុវត្តបានល្អប្រសើរ ទៀងទាត់ ទាន់ពេលវេលា តាមរយៈការអនុវត្តការបើកផ្តល់តាមប្រព័ន្ធធនាគារ ដែលនេះជាជោគជ័យដ៏ធំធេងរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះដែររាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ផងដែរដល់ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូននិវត្តន៍ជន។

លទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានបង្ហាញថា តាមចលនានៃការកែទម្រង់លើគ្រប់វិស័យ និងកាន់តែស៊ីជម្រៅ រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាក្រោមការដឹកនាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បាននិងកំពុងតែធ្វើដំណើរផ្លាស់ប្តូរ ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាបក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

**៣-បញ្ហាផ្សេងៗ៖**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ ក្រើនរំលឹកដល់អាជ្ញាធរ រាជធានី ខេត្ត កងកម្លាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធ សហការគ្នាបង្កើនការរកចំណូលថវិកាជាតិ ដោយទប់ស្កាត់សកម្មភាពរត់គេចពន្ធ និងការមិនបង់ពន្ធ ក៏ដូចជាណែនាំឲ្យក្រសួង ស្ថាប័នរដ្ឋនានា ត្បិតត្បៀតនូវការចំណាយណាដែលមិនចាំបាច់។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង ៥០ នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥